**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧៩ អនក្រ**

# សេចក្តីសម្រេច

# ស្តីពី

# ការតែងតាំងសមាសភាពក្រុមការងារ កសាងប្រព័ន្ធធារាសាស្ត្រ ស្រុកគិរីវង្ស ខេត្តតាកែវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានតែងតាំងសមាសភាពក្រុមការងារកសាងប្រព័ន្ធធារាសាស្ត្រ ស្រុកគិរីវង្ស ខេត្តតាកែវ ដូចមានឈ្មោះខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សេង លឹមនៅ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **វង់ សារ៉ែត** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣- ឯកឧត្តម | **ម៉ៅ ថូរី** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤- ឯកឧត្តម | **ឌា ជុំ** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៥- ឯកឧត្តម | **គង់ អ្នក** | អនុប្រធានគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ | សមាជិក |
| ៦- លោក | **ទាំង ប៊ូ** | អនុប្រធានក្រុមហ៊ុន CAMCE | សមាជិក |

www.pheakdeylaw.com

**ប្រការ ២.-** ក្រុមការងារកសាងប្រព័ន្ធធារាសាស្ត្រ ស្រុកគិរីវង្ស ខេត្តតាកែវ មានភារកិច្ច :

- សហការជួយគ្នាទៅវិញទៅមក ក្នុងការបំពេញកាតព្វកិច្ចរៀងៗខ្លួន សម្រាប់ការអភិវឌ្ឍគម្រោង
- ផ្តល់ព័ត៌មាន និងទិន្នន័យចាំបាច់សម្រាប់គម្រោង
- ផ្តល់ការយល់ព្រមលើការសិក្សា សមិទ្ធិ លទ្ធភាពគម្រោង ដោយអនុវត្តតាមវិជ្ជាជីវៈ និងបទពិសោធន៍ បច្ចេកទេសរបស់ក្រុមហ៊ុន
- ជួយសម្របសម្រួល និតិវិធីគម្រោង ដើម្បីសុំការយល់ព្រមពីរាជរដ្ឋាភិបាល ។
- សហការ និងជួយសម្របសម្រួលការអនុវត្តប្រាក់កម្ចីសម្រាប់គម្រោង ( ប្រាក់កម្ចីអនុគ្រោះពិសេស Preferential Loan ពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ) ។

**ប្រការ ៣.-** ក្រុមការងារកសាងប្រព័ន្ធធារាសាស្ត្រ ស្រុក គិរីវង្ស ខេត្ត តាកែវ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ ៤
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com